COMMITTEE TO PROMOTE WOMEN IN POLITICS

CPWP

Secretariat Address: C/O SILAKA # 6 S, Street 21, Sangkat Tonle Bassac,
Khan Chamcar Mon, Phnom Penh, Cambodia
Tel: (855) 23 217 872/ 210 902; Fax: (855) 23 213 108; Email: thida_khus@silaka.org

# គណៈកម្មាធិការលើកស្ទួយស្ត្រី ក្នុងវិស័យនយោបាយ "គសន"

## ១. បុព្វកថា :

- ដោយយើងយល់ថាស្ត្រី និងបុរសត្រូវមានសិទ្ធិស្មើគ្នាក្នុងការទទួលបាននូវឱកាស និងផលប្រយោជន៍ពីសង្គម
- ដោយហេតុថា រាល់ការអភិវឌ្ឍ និងការកាត់បន្ថយភាពក្រីក្រមិនអាចកើតឡើងបានទេ បើគ្មានការចូលរួមពីស្ត្រី និងបុរសដោយស្មើភាពគ្នានោះ
- ដោយហេតុថា នារីមានប្រមាណជាង ៥២% នៃប្រជាពលរដ្ឋខ្មែរសរុប និងចំនួនស្ត្រី ៨២% សកម្មក្នុងវិស័យសេដ្ឋកិច្ច
- ដោយហេតុថា នៅកម្ពុជាមានការរើសអើងចំពោះស្ត្រីយ៉ាងធំធេងទាំងក្នុងការទទួលបានការអប់រំ ទាំងឱកាសចូលរួមធ្វើសេចក្តីសម្រេចចិត្តក្នុងមុខងារសាធារណៈ ក្នុងវិស័យនយោបាយ ហើយប្រទេសកម្ពុជា ក៏ជាហត្ថលេខី លើ អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទំរង់នៃការរើសអើង ប្រឆាំងនឹងនារីភេទ (CEDAW) ផងដែរ
- ដោយហេតុថា ឫសគល់វប្បធម៌ខ្មែរធ្លាប់បានផ្តល់តួនាទីក្នុងភាពជាអ្នកដឹកនាំ និងការគោរពចំពោះនារីទាំងនៅក្នុងក្រុមគ្រួសារ និងក្នុងសង្គម
- ដោយហេតុថា គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្រចតុកោណ ទាមទារឱ្យមានការកែលំអការចូលរួមរបស់ស្ត្រីដែលជាមធ្យោបាយ នាំទៅរកការអភិវឌ្ឍប្រកបដោយប្រសិទ្ធភាព និងមានចីរភាពយូរអង្វែង។
- ដោយហេតុថា យើងរក្សានូវអព្យាក្រឹតភាពខាងនយោបាយរបស់ខ្លួន ដោយមិនប្រកាន់យកគណបក្សនយោបាយណាមួយ ឬប្រឆាំងនឹងគណបក្សណាមួយឡើយ

- ដោយហេតុថា ដើម្បីកែលំអសភាពការណ៍បច្ចុប្បន្ន យើងត្រូវការឱ្យមានកិច្ចសហការសម្របសម្រួល ប្រឹងប្រែង ចូលរួមពីសមាជិកសកម្មទាំងឡាយក្នុងសង្គម។

**គណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ** (**គសន**) បានចាប់បដិសន្ធិឡើងនៅឆ្នាំ២០០៥ ជាសម្ព័ន្ធអង្គការសមាគមមិនមែនរដ្ឋាភិបាលក្នុងស្រុកចំនួន ៧ មាន : អង្គការសិលការ (SILAKA) អង្គការ យេនឌ័រនិងអភិវឌ្ឍន៍ដើម្បីកម្ពុជា (GAD/C) អង្គការខុមហ្វ្រែល (COMFREL) អង្គការនិកហ្វិច (NICFEC) អង្គការចំរើនស្ត្រី (Women For Prosperity) សមាគមនារីកម្ពុជាដើម្បីសន្តិភាព និង អភិវឌ្ឍន៍ (CWPD) និងវិទ្យាស្ថានស្រាវជ្រាវដើម្បីអភិវឌ្ឍន៏កម្ពុជា (CDRI)។

## ២. ទស្សនវិស័យ និងបេសកកម្ម របស់ គសន

គណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ (គសន ) មានទស្សនវិស័យថា សង្គមកម្ពុជា ស្ត្រី និងបុរសមានសិទ្ធិស្មើគ្នាក្នុងការទទួលបានឱកាស និងផលប្រយោជន៏ពីសង្គម។

ដើម្បីសម្រេចដល់ទស្សនវិស័យខាងលើ **គសន** ត្រូវបានកំណត់បេសកកម្មដូចខាងក្រោម :

- លើកស្ទួយស្ត្រី និងបុរសឱ្យមានការចូលរួមស្មើៗគ្នាក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងឈរឈ្មោះ ជាតំណាងក្នុងមុខងារសាធារណៈ ។
- សហការគ្នាអភិវឌ្ឍ និងអនុវត្តការងារដោយសកម្ម ដើម្បីជួយជ្រោមជ្រែងបង្កើនសមាមាត្រស្ត្រីក្នុងការចូលរួមការងារសង្គម និងនយោបាយ ។

## ៣. ការប្រឈមមុខបច្ចុប្បន្ននៅថ្នាក់រដ្ឋបាលមូលដ្ឋាន

ការអនុវត្តអភិបាលកិច្ចល្អតាមនយោបាយវិមជ្ឈការ កម្ពុជាបានអនុម័តច្បាប់ស្តីពី *"ការគ្រប់គ្រង រដ្ឋបាលឃុំ/សង្កាត់"* និងបានរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់លើកដំបូងនៅឆ្នាំ២០០២។ ដំណើការវិមជ្ឈការរូបនីយកម្ម និងការបោះឆ្នោតដោយប្រជាពលរដ្ឋដើម្បីជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់បានផ្តល់ឱ្យប្រជាពលរដ្ឋចូលរួមយ៉ាងពេញលេញក្នុងសកម្មភាពអភិវឌ្ឍន៍ ការគ្រប់គ្រង និងការសម្រេចចិត្តនៅថ្នាក់រដ្ឋបាលមូលដ្ឋានដែលជះឥទ្ធិពលទៅលើកជីវភាពរស់នៅប្រចាំថ្ងៃ។

ក្រុមប្រឹក្សា ឃុំ/ សង្កាត់អាចជួយបង្កើត និងជម្រុញឱ្យមានបរិយាកាសជាផ្លែផ្កាស្របនឹងស្ថានភាព ជាក់ស្តែងនៃតុល្យភាពយេនឌ័រដែលធ្វើឱ្យសិទ្ធិស្ត្រីនិងបុរសត្រូវបានការពារ និងមាន ភាពរីកចំរើន។

កម្ពុជាមានឃុំ/សង្កាត់សរុបចំនួន១.៦២១។ បេក្ខជនបេក្ខនារីច្រើនជាង ៧៦.០០០នាក់ ក្នុងនោះមាន១២.០០០ជានារី(១៦%)ដែលមកពីគណបក្សនយោបាយចំនួន៨ បានចូលរួមក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់នាឆ្នាំ២០០២ ។ ជារួមមានសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ចំនួន ១១.២៦១នាក់ត្រូវបានជាប់ឆ្នោត ដែលមានសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ជាស្ត្រីចំនួនតែ ៩៨៣នាក់ (៩%) ប៉ុណ្ណោះ។ ២/៣ នៃសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ទាំងអស់នៅប្រទេសកម្ពុជាមិនមានតំណាងស្ត្រីនោះទេ។ នេះជាហេតុផល ដែលស្ត្រីជាធម្មតាមិនត្រូវបានគេដាក់នៅផ្នែកខាងលើនៃបញ្ជីបេក្ខជនឈរឈ្មោះរបស់គណបក្សនយោបាយ ក្នុងអំឡុងពេលបោះឆ្នោត ធ្វើឱ្យស្ត្រីមានឱកាសតិចតួចដើម្បីបានជាប់ឆ្នោត ។ អនុវត្តតាមវិធានដូចនេះ ស្ត្រីក៏មិនអាចមានលទ្ធភាពទៅទទួលតួនាទីសំខាន់ៗ ដូចជាប្រធានក្រុមប្រឹក្សាឃុំ/សង្កាត់ ជំទប់ទី១ ជំទប់ទី២ ឬចៅសង្កាត់រងទី១ ចៅសង្កាត់រងទី២នៃក្រុមប្រឹក្សាឃុំ/សង្កាត់ ផងដែរ ។ នៅឆ្នាំ២០០៣ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ២២ ប្រកាសថា

នៅគ្រប់ក្រុមប្រឹក្សាឃុំ/សង្កាត់ក្នុងព្រះរាជណាចក្រកម្ពុជាគួរមានជនបង្គោលជាស្ត្រី ទទួលបន្ទុកការងារស្ត្រី និងកុមារ។ ទោះបីជាយ៉ាងណាក៏ដោយ តាមការវាយតម្លៃរបស់កម្មវិធីយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័ររបស់កម្មវិធីសិលា ឆ្នាំ២០០១-២០០៥ បានបង្ហាញអំពីអវត្តមានរបស់ជនបង្គោលទទួលបន្ទុកការងារស្ត្រី និងកុមារនៅឃុំ/សង្កាត់ ហើយមានចំនួនជនបង្គោលទទួលបន្ទុកការងារស្ត្រី និងកុមារជាច្រើនត្រូវបានរកឃើញថាមានការខ្វះខាតសមត្ថភាព ក្នុងការបំពេញការងាររបស់ខ្លួន ។

វត្តមានរបស់ស្ត្រី អាចមានលទ្ធភាពធ្វើឱ្យគោលនយោបាយ និងជម្រុញការធ្វើអន្តរាគមន៍ដល់សិទ្ធិស្ត្រី និងកុមារនៅក្នុងក្រុមប្រឹក្សាឃុំ/សង្កាត់អោយមានប្រសិទ្ធភាព។ ជាងនេះទៅទៀតស្ត្រីមានចំនួនជាង៥២%នៃចំនួនប្រជាពលរដ្ឋទាំងអស់ ប៉ុន្តែការផ្តល់សិទ្ធិដល់ស្ត្រីអោយបាននូវឱកាសក្នុងតួនាទីតាក់តែងគោលនយោបាយ និងការធ្វើសេចក្តីសំរេចចិត្តនៅ មានចំនួនតិចតួច ព្រោះថាតួនាទីទាំងនេះ គឺជាមូលដ្ឋានគ្រឹះ នៃការចូលរួមដ៏ពេញលេញ តាមបែបប្រជាធិបតេយ្យ។ បើប្រៀបធៀបជាមួយបុរស ស្ត្រីជាសមាជិកក្រុមប្រឹក្សា ឃុំ/សង្កាត់ ក៏អាចដោះស្រាយបានភ្លាមៗ លើបញ្ហាសង្គម ដូចជា សុខភាព ការអប់រំ អំពើហិង្សាផ្អែកយេនឌ័រ និងការរើសអើងលើស្ត្រីភេទ ព្រមទាំងការកសាងសហគមន៍ ដូចបុរសដែរ ។ ស្របពេលជាមួយគ្នានេះដែរ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាស្ត្រី ត្រូវការនូវការផ្តល់សិទ្ធិអំណាច ដោយមិនមានការរើសអើង ក្នុងការកសាងសមត្ថភាពជំនាញ និងការគាំទ្រ ទាំងសម្ភារៈ និងហិរញ្ញវត្ថុ ព្រមទាំងទទួលបានអារម្មណ៍សុវត្ថិភាព ដើម្បី អនុវត្ត តួនាទី និងភារកិច្ចរបស់ខ្លួន ឱ្យអស់ពីសមត្ថភាព ។

## ៤. ដំណោះស្រាយ

ជម្រុញដល់គណបក្សនយោបាយឱ្យអនុវត្តប្រព័ន្ធកូតា ឬបង្កើនសមាមាត្រស្ត្រី ដែលធានាថា យ៉ាងហោចណាស់អោយមានបេក្ខភាពចំនួន៣០%ជាស្ត្រី ក្នុងរូបមន្ត ២៥%ជាបេក្ខនារីពេញសិទ្ធិ និង ៥%ជាបេក្ខនារីបម្រុង ។ ប្រព័ន្ធនេះដែរនឹងធានា ដល់ការដាក់បេក្ខជនជា

ស្ត្រី និងបេក្ខជនជាបុរសឆ្លាស់គ្នា នៅបញ្ជីឈ្មោះផ្នែកខាងលើ (Top List) សំរាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ នាឆ្នាំ២០០៧ ខាងមុខ។

## ៥. យុទ្ធសាស្ត្រ

គណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ អនុវត្តសកម្មភាព តាមរយៈប្រព័ន្ធផ្សព្វផ្សាយក្នុងវេទិកាសាធារណៈ វគ្គបណ្តុះបណ្តាលដល់ស្ត្រី សិល្បៈអប់រំ ការបញ្ចុះបញ្ចូល និងការតស៊ូមតិ និងការផ្សព្វផ្សាយឯកសារអប់រំ ដើម្បីលើកកម្ពស់ការយល់ដឹងជាសាធារណៈ និងស្វែងរកការគាំទ្រពីប្រជាពលរដ្ឋ និងពីគណបក្សនយោបាយ ។

## ៦. គោលដៅ និងសកម្មភាព

### គោលដៅ

- បង្កើនចំនួនស្ត្រី ជាសមាជិកក្រុមប្រឹក្សាឃុំពី៩% ទៅ១៥ % សំរាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០០៧ ដោយជំរុញឱ្យគណបក្សនយោបាយអនុវត្តតាមប្រព័ន្ធកូតា ឬ បង្កើនសមាមាត្រ ៣០% ជាស្ត្រី ដោយដាក់បេក្ខជនជាស្ត្រី និងបេក្ខជនជាបុរសឆ្លាស់គ្នានៅក្នុងបញ្ជីឈ្មោះផ្នែកខាងលើ ។
- ជម្រុញអង្គការ សមាគមមិនមែនរដ្ឋាភិបាល និងស្ថាប័នព័ត៌មានទាំងឡាយអំពីស្ត្រី ដើម្បីធ្វើឱ្យជ្រួតជ្រាប ជាសាធារណៈ អំពីយេនឌ័រ និងសារៈសំខាន់នៃតំណាងស្ត្រីជាសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ ។
- បង្កើនសមត្ថភាព អង្គការមិនមែនរដ្ឋាភិបាល ដើម្បីហ្វឹកហ្វឺនបេក្ខនារី ក្នុងការលើកគំរោង រៀបចំ និងគ្រប់គ្រងយុទ្ធនាការឃោសនា និងវេទិកាសាធារណៈ ដោយផ្អែកលើការរួមគ្នាចែករំលែកបទពិសោធន៍ ឯកទេស ចំណេះដឹង និងធនធានដល់គ្នានឹងគ្នា ។

## សកម្មភាព

**១. បញ្ចុះបញ្ចូល និងតស៊ូមតិ អំពី "ធ្វើការជាមួយគ្នា ដើម្បីបង្កើនចំនួនស្ត្រី ជាតំណាងអ្នកបោះឆ្នោត"**

- រៀបចំជំនួបជាផ្លូវការ និងក្រៅផ្លូវការ ជាមួយមន្ត្រីថ្នាក់ជាតិដែលពាក់ព័ន្ធនឹងគណបក្សនយោបាយ ស្ថាប័នពាក់ព័ន្ធដែលមានឥទ្ធិពល និងជាមួយព្រះមហាក្សត្រ ដើម្បីសុំការឧបត្ថម្ភ និងគាំទ្រ ហើយអាចជំរុញឱ្យមានការផ្លាស់ប្តូរ តាមគោលដៅ ដូចមានចែងខាងលើ ។
- កសាងទំនាក់ទំនងល្អជាមួយអាជ្ញាធរដែនដី រដ្ឋាភិបាល និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ដើម្បីលុបបំបាត់រាល់រូបភាពនៃការរើសអើង និងហិង្សាទៅលើស្ត្រី ។

**២. ហ្វឹកហ្វឺនអំពី "ការពង្រឹងស្ត្រីក្នុងការសំរេចចិត្ត"**

- បើកវគ្គហ្វឹកហ្វឺនចំនួន ៣ ថ្ងៃ អំពីចំណេះដឹងលើវិស័យនយោបាយ ការឃោសនាបោះឆ្នោត ការរកថវិកា កសាងបណ្តាញការងារអ្នកស្ម័គ្រចិត្ត និងភារកិច្ចទទួលខុសត្រូវ នៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ សំរាប់អនាគតបេក្ខនារី ។

**៣. ផ្សព្វផ្សាយយុទ្ធនាការតស៊ូមតិ ក្នុងប្រធានបទ "បោះឆ្នោតឱ្យគណបក្សដែលមានឈ្មោះបេក្ខនារី នៅជួរលើ "**

- ពិភាក្សាតុមូល និងផលិតឧបករណ៍អប់រំ ដូចជាខារាអូខេ ស្ប៉ត តាមទូរទស្សន៍ វិទ្យុ និងខ្សែអាត់នៅទូទាំងប្រទេស ហើយក្នុងនោះ ប្រធានបទដែលលើកមកនិយាយ អាចស្តីអំពីយេនឌ័រ និងការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ និងគំរូល្អនៃសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ជាស្ត្រី ព្រមទាំងគ្រួសាររបស់គេដែលបានលើកទឹកចិត្តឱ្យគេជាស្ត្រីមកឈរជាបេក្ខជន ។
- សំដែងល្ខោន អំពីផលប្រយោជន៍ដែលស្ត្រីជាមគ្គុទេសក៏។

**៤. វេទិកាសាធារណៈ ជុំវិញប្រធានបទ"សុខមាលភាពសង្គម និងស្ត្រី ក្នុងការសំរេចចិត្ត"**

- រៀបចំវេទិកាសាធារណៈ ដែលមានការចូលរួមពីអ្នកដឹកនាំ និងអាជ្ញាធរដែនដី និងអ្នកបោះឆ្នោត ក្នុងការពិភាក្សា ក៏ដូចជាល្បែងកំសាន្ត ដែលមានលក្ខណៈអប់រំ ។

**៥.ការស្ទង់មតិដើម្បីស្វែងរកយល់ឃើញចំពោះភាពជាអ្នកដឹកនាំជាស្ត្រីនៅតាមថ្នាក់មូលដ្ឋាន**

លទ្ធផលពីការស្ទង់មតិនេះនឹងជូនជាព័ត៌មានដល់

- រដ្ឋាភិបាលក្នុងការបង្កើតគោលនយោបាយ
- គណបក្សនយោបាយក្នុងការរៀបចំវេទិកាសំរាប់ពេលបោះឆ្នោតខាងមុខ
- សង្គមស៊ីវិលនៅប្រទេសកម្ពុជា ក្នុងការរៀបចំយុទ្ធសាស្ត្រតស៊ូមតិ និងជាព័ត៌មានដើម្បីបង្កើតជាយុទ្ធនាការផ្សព្វផ្សាយ និងអប់រំដើម្បីជម្រុញឱ្យមានតំណាងស្ត្រី និងស្ត្រីក្នុងភាពជាអ្នកដឹកនាំ ក្នុងវិស័យនយោបាយកាន់តែច្រើនឡើងទៀត ។

យើងខ្ញុំសូមស្វាគមន៍ ចំពោះស្ថាប័ន និង បុគ្គលដែលមានគោលដៅ និងគោលបំណងដូចគណៈកម្មាធិការ ។ សូមអញ្ជើញទំនាក់ទំនងមកលេខាធិការដ្ឋានរបស់គណៈគម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យ នយោបាយ ។

# Committee to Promote Women in Politic

## *Term of References*

### I. Preamble:

- Whereas we believe that women and men should enjoy equal access to opportunity and benefit from society;
- Whereas all development and the reduction to poverty cannot take place without the equal involvement of women and men;
- Whereas women make more than 52% of the total population and 82% of the economically active population;
- Whereas there are wide discrimination on women in Cambodia in accessing education, having opportunity to participate in decision making and in politic; Further : Cambodia is a signatory to the Convention on the Elimination of Discrimination Against Women, (CEDAW);
- Whereas the Cambodian cultural roots believe in giving the leadership role and respect to women in family and society;
- Whereas the Cambodian Development Goals, the Cambodian Strategic Plan, and the Government's Rectangular Strategy call for the improvement of women participation as the means to development effectiveness and sustainability;
- Whereas we believe in maintaining our political neutrality, we will not be favoring any one political party over another;
- Whereas we believe that to redress the situation, we need a coordinated effort from active members of society to participate.

**Be resolved to organize the Committee to Promote Women in Politic (CPWP)** in 2005, with founding member organizations, namely SILAKA, GAD/C, COMFREL, NECFEC, Women for Prosperity (WFP), Cambodian Women for Peace and Development (CWPD), and Cambodia Development Research Institute (CDRI).

## II. Vision and Mission:

The Committee to Promote Women in Politic, CPWP has the vision of a Cambodian society in which women and men enjoy equal access to opportunity and benefits from society.

To reach the above vision, CPWP, has adopted the coordinated action for the following mission:

- To promote women and men equal participation in decision making and representation in public office;
- To collaborate with each other in developing and implementing joint activities to further the advancement of women in Cambodian society.

## III. Current Challenges:

Cambodia has implemented the decentralization in Cambodia by approving *Local Administration law for Communes and Sangkat* and organizing a local election in February 2002 to select communes/sangkats counselors. The election has prepared the ground to allow local communities to take full responsibility for their own development and local administration, the key pillars that impact on their daily life.

Commune and Sangkat Councils members were elected to support local development to fit with local context, to assure the respect of women rights and human rights at all time.

Cambodian has a total of 1,621 communes and sangkat. In the 2002 election, the number of counselor candidates were over 76,000, among them 12,000 (16%) were women coming from 8 political parties. Among the candidates, 11,261 were elected, among whom only 983 (9%) were women. Among the total communes and sangkat, 2/3 does not have women counselors. The reason of this low level of elected women candidates was that women candidates were not place on top of the list of the political parties' candidates. This practice has disfavored them in the

current proportionate election system. Therefore, only a few women were elected to hold important position in the commune and sangkat councils. In 2003, the government has issued a declaration No. 22 to demand that all communes and sangkats have women as the head of women and children affairs. However, according to the evaluation of SEILA program 2001-2005 found out that those women lacks the capacity to fulfill their roles.

Women's presence in politic would push for an effective program intervention for women and children at the communes and sangkats. Further, women made up of 52% of the overall population. However, women do not enjoy the access to full and equal representation and participation in decision making on matters that affect their own lives. Women have a tendency to give more priorities to families' problems, such as health, education, family violence, and community development more than men do. Moreover, current elected women commune counselors must be given their full rights to exercise their power and duty without discrimination, and need further training to develop their capacity and full potentials to serve their community.

## IV. Solution

To promote the adoption of quota system among political parties to guaranty the increase the number of women elected to 30% in a formula of 25% full rights with a back up number to 5%. This formula will require that the listing of candidates list be alternate between the sexes in 2007 commune and sangkat election.

## V. Strategy

CPWP will implement activities through media campaign through the outlets of the media, public forums, training of women candidates, media drama, advocacy and lobbying to promote the awareness the importance of women participation in decision making at the local level, among the general public and the political parties.

## VI. Goal and Activities

**Goals:**

- Increase women in commune and sangkats from 9% to 15% in 2007 through promoting political parties using 30% quota system and in place women candidates at the top list.
- Promote NGO and associations and the media to support the promotion to the above goal to the general public on the importance of gender and women representatively in the communes and sangkats.
- Increase the capacity of local organizations to increase capacity of women candidates in developing proposal, organizing, and implementing their campaign in public forums based on sharing knowledge, techniques, experiences and resources.

**Activities:**

1. **Advocacy and lobbying** under the theme *"Working together to increase women representatives in the election.*
    - Organize high level meetings officially and unofficially with influential officials, such as Ministers, National political parties leaders, and the King to seek support to the women agenda stated above.
    - Engage with local authorities, government, and the National Election commission with the purpose to eliminate all form of discrimination and violence against women.
2. **Training to women candidates** on: *Women in Decision Making.*
    - Organize 3 days training to candidates from political parties. Topics for training include: What is politic, How to mount an election campaign, set up a fund raising project, how to building network of volunteers and the role of the members of the sangkat and commune councils.

**3. Advocacy campaign through the media** with the theme: *Vote for political parties with women candidates at the top list*

- Round table discussion, develop materials for information campaign such as Karaok, TV and radio spots, to be broadcasted throughout the country. Theme of the campaign will be issue on gender, the sangkat/commune election and the role model of women commune counselors, on what they brought to their communes and how their families have supported them.
- Drama session on the theme set above.

**4. Public Forum** on the theme: *Social Development and Women in Decision Making.*

- Organize public forum with the participation from leaders, local authorities, and electors to discuss on the issue and participate in educational activities on the subject.

**5. Survey** *to find out the perception on women leadership at the grassroots level*

- Help inform government policy making, the platforms of political parties in forthcoming elections, and the advocacy strategies and messages of civil society organizations in Cambodia in developing media and education campaign to promote greater political representation and leadership of women.

We would welcome organizations and individuals who believe in the same goal and objectives; Please contact the CPWP secretary.

**SILAKA**
#6 S, Street 21, Tonle Bassac, Chamcarmorn, Phnom Penh.
Tel/Fax: (855-23) 217-872/ 213-108
Email: silaka@silaka.org; Website:www.silaka.org

**Gender and Development for Cambodia (GAD/C)**
#89, Street 288, Olympic, Chamcarmorn, Phnom Penh.
Tel/Fax: (855-23) 215-137/ 996-934
Email: gad@online.com.kh; Website: www.online.com.kh/~gad

**Women For Prosperity (WFP)**
# 17, Street 430, Psar Deum Thkov, Chamcarmorn, Phnom Penh
Tel/Fax: (855-23) 212-429/ 212-447 Email:wfpnp@online.com.kh

**Committee for Free and Fair Election in Cambodia (COMFREL)**
#138, Street 122, Tuk Laak 1, Tuol Kork, Phnom Penh
Tel/Fax: (855-23)883-967
Email: comfrel@forum.org.kh; Website: www.comfrel.org

**Cambodia Development Research Institute (CDRI)**
# 56, Street 315, Boeng Kak, Tuol Kork, Phnom Penh
Tel/Fax: (855-23) 881-384
Email: cdri@camnet.com.kh; Website: www.cdri.org.kh

**Cambodian Women for Peace and Development (CWPD)**
# 23, Rue de France 47, Sras Chork, Daun Penh, Phnom Penh.
Tel/Fax: (855-23) 724-274;
Email: cwpdtr@online.com.kh

**Neutral and Impartial Committee for Free and Fair Election in Cambodia (NICFEC)**
#16D, St 348, Boeng Keng Kang III, Chamcarmorn, Phnom Penh.
Tel/Fax: (855-23) 993-037 Eamil: nicfec@camintel.com

Secretariat Address: C/O SILAKA # 6 S, Street 21, Sangkat Tonle Bassac,
Khan Chamcar Mon, Phnom Penh, Cambodia
Tel: (855) 23 217 872/ 210 902; Fax: (855) 23 213 108; Email: thida_khus@silaka.org